API
BUILDING CAPACITY FOR CHANGE

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា
The NGO Forum on Cambodia

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

លេខៈ...002...../BWG/២០២៤

**សូមគោរពជូន**
**សម្ដេចរដ្ឋសភាធិបតី ឃួន សុដារី**
**ប្រធាន រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុៈ** គោរពផ្ញើជូននូវមតិយោបល់ពីក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលលើច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ និងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំផែនការថវិកាសម្រាប់ឆ្នាំសារពើពន្ធបន្ទាប់។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ តាងនាមក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដែលសម្របសម្រួលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា យើងខ្ញុំសូមសម្ដែងនូវការកោតសរសើរ និងអបអរសាទរដល់រាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានខិតខំបំពេញភារកិច្ច ប្រកបដោយការវិវត្តជាវិជ្ជមាននាពេលកន្លងមក ជាពិសេសក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧។

យើងខ្ញុំសូមគោរពជម្រាបជូន **សម្ដេចរដ្ឋសភាធិបតី** មេត្តាជ្រាបថា ក្រុមការងារថវិកា បានពិនិត្យមើល ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ព្រមទាំងឯកសារពាក់ព័ន្ធទាំងឡាយដោយយកចិត្តទុកដាក់បំផុត។ ជាលទ្ធផល ក្រុមការងារបានចងក្រង ជាមតិយោបល់ទៅលើច្បាប់ ដូចដែលបានភ្ជាប់ជូនមកជាមួយនេះ ជូនដល់រដ្ឋសភាដើម្បីជាធាតុចូលក្នុងការជជែកពិភាក្សាជាមួយស្ថាប័នរាជរដ្ឋាភិបាល នាពេលខាងមុខនេះ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ យើងខ្ញុំសូម **សម្ដេចរដ្ឋសភាធិបតី** មេត្តាទទួលយកនូវមតិយោបល់នេះដោយក្ដីអនុគ្រោះ **និងសូមអនុញ្ញាតស្នើឲ្យមានជំនួបពិភាក្សាជាមួយគណៈកម្មការទី២ លើឯកសារនេះក្នុងពេលឆាប់ៗតាមការរៀបចំរបស់រដ្ឋសភា។**

សូម **សម្ដេចរដ្ឋសភាធិបតី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃចន្ទ ៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២៤
**ជ. ក្រុមការងារថវិកានៃអង្គការ**

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ លោក ម៉ារ សុផល
ប្រធានគ្រប់គ្រងកម្មវិធី នៃអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា តាមរយៈទូរសព្ទៈ 012 845 091
ឬ អ៊ីម៉ែលៈ sophal@ngoforum.org.kh

| | | |
|---|---|---|
| **នាយកប្រតិបត្តិ** | **នាយកប្រតិបត្តិអង្គការវេទិកានៃ** | **នាយកប្រតិបត្តិ** |
| **វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ** | **អង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា** | **អង្គការតម្លាភាពកម្ពុជា** |
| **លោក ឡាំ សុជាតិ** | **លោក សឿង សារឿន** | **លោក ប៉ិច ពិសី** |

API BUILDING CAPACITY FOR CHANGE

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

លេខ:.០០៤....../BWG/២០២៤

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ៖** គោរពផ្ញើជូននូវ មតិយោបល់ពីក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលលើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ និងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំផែនការថវិកាសម្រាប់ឆ្នាំសារពើពន្ធបន្ទាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ តាងនាមក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដែលសម្របសម្រួលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអបអរសាទរដល់រដ្ឋសភា និងរាជរដ្ឋាភិបាល ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយការវិវត្តជាវិជ្ជមាននាពេលកន្លងមក ជាពិសេសក្នុងការចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧។

យើងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាជ្រាបថា ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល បានពិនិត្យមើល និងឈ្វេងយល់ឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ដោយយកចិត្តទុកដាក់បំផុត។ ជាលទ្ធផល ក្រុមការងារថវិកាបានចងក្រងជាមតិយោបល់ទៅលើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ដូចដែលបានភ្ជាប់ជូនមកជាមួយនេះ ជូនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជាធាតុចូលក្នុងការជជែកពិភាក្សាជាមួយស្ថាប័នរាជរដ្ឋាភិបាលក្នុងឆ្នាំខាងមុខនេះទៀត។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ យើងខ្ញុំសូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាទទួលយកនូវមតិ យោបល់នេះដោយក្តីអនុគ្រោះ និង**សូមស្នើឱ្យមានជំនួបពិភាក្សាលើឯកសារនេះក្នុងពេលឆាប់ៗនេះតាមការរៀបចំរបស់ក្រសួង។**

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ។

ថ្ងៃចន្ទ ៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២៤

ជ. ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ លោក ម៉ារ សុផល
ប្រធានគ្រប់គ្រងកម្មវិធី នៃអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា តាមរយៈទូរសព្ទ: 012 845 091
ឬ អ៊ីម៉ែល: sophal@ngoforum.org.kh

| | | |
|---|---|---|
| **នាយកប្រតិបត្តិ** | **នាយកប្រតិបត្តិអង្គការវេទិកានៃ** | **នាយកប្រតិបត្តិ** |
| **វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ** | **អង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា** | **អង្គការតម្លាភាពកម្ពុជា** |
| **លោក ឡាំ សុជាតិ** | **លោក សឿង សារឿន** | **លោក ម៉ិច ពិសី** |